**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងទទួលធ្វើជាម្ចាស់ផ្ទះនូវកម្មវិធីចំនួន៣ ស្តីពីបណ្តាញសុខភាព និងសុវត្ថិភាពការងារអាស៊ាន (ASEAN-OSHNET) ដែលនឹងប្រព្រឹត្តទៅនាថ្ងៃច័ន្ទ ២រោច ដល់ថ្ងៃពុធ ៤រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស២៥៦១ ត្រូវនឹងថ្ងៃទី០២-០៤ ខែមេសា ឆ្នាំ២០១៨ នៅសណ្ឋាគារ Empress Angkor Resort and Spa Hotel ខេត្តសៀមរាប ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបើកដោយ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង **ឯកឧត្តម** Dato' Lim Jock Hoi អគ្គលេខាធិការអាស៊ាន។

១-កិច្ចប្រជុំប្រចាំឆ្នាំលើកទី១៩របស់បណ្តាញសុខភាព និងសុវត្ថិភាពការងារអាស៊ាន (The 19th ASEAN-OSHNET Coordinating Board Meeting)

២- ពិធីផ្តល់ពានរង្វាន់បណ្តាញសុខភាព និងសុវត្ថិភាពការងារអាស៊ានលើកទី២ដល់សហគ្រាសដែលបានអនុវត្តសុខភាព និងសុវត្ថិភាពការងារល្អ និងល្អឥតខ្ចោះ (The 2nd ASEAN-OSHNET Awards Ceremony)

៣- សន្និសីទបណ្តាញសុខភាព និងសុវត្ថិភាពការងារអាស៊ានលើកទី៥ ក្រោមប្រធានបទ *"សុខភាព និងសុវត្ថិភាពការងារ និងសំណងគ្រោះថ្នាក់ការងារនៅក្នុងវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងកន្លែងធ្វើការនៅតាមជនបទ"* (The 5th ASEAN-OSHNET Conference)។

ព្រឹត្តិការទាំងនេះ មានការចូលរួមដោយថ្នាក់ដឹកនាំផ្នែកសុខភាព និងសុវត្ថិភាពការងារ នៃប្រទេសសមាជិកអាស៊ាន រដ្ឋបាល នៃរដ្ឋការផ្នែកសុខភាព និងសុវត្ថិភាពការងារនៃសាធារណៈប្រជាមានិតចិន (SAWS) ក្រសួងសុខាភិបាល ការងារ និងសុខមាលភាពប្រទេសជប៉ុន (MHLW) ទីភ្នាក់ងារសុខភាព និងសុវត្ថិភាពការងារកូរ៉េ (KOSHA) អង្គការអន្តរជាតិខាងការងារ (ILO) សមាគមអធិការកិច្ចការងារអន្តរជាតិ (IALI) អង្គការសុខភាព និងសុវត្ថិភាពការងារអាស៊ីប៉ាស៊ីហ្វិក (APOSHO) សមាគមសន្តិសុខសង្គមអន្តរជាតិវិស័យរ៉ែ (ISSA Mining) តំណាងសហគ្រាសគ្រឹះស្ថាននៃបណ្តាប្រទេសជាសមាជិកអាស៊ាន តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងនិយោជក និងកម្មករនិយោជិត សរុបប្រមាណជាង ២០០នាក់។

*រាជធានីភ្នំពេញ ថ្ងៃចន្ទ ១០កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១*

*ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨*